# អំពីស្ត្រី

## «ស្ត្រីចូលរួមក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងការងារសង្គមជាតិ»

## ១. សេចក្តីផ្តើម

ទិវាសិទ្ធិនារីអន្តរជាតិ ៨មិនា គឺជាប្រវត្តិរបស់នារីសាមញ្ញមួយចំនួនដែលបានបង្កើតឲ្យមានប្រវត្តិសាស្ត្រនេះឡើង ។ ទិវានេះបានចាក់ឫសយ៉ាងជ្រៅអស់រយៈពេលជាច្រើនទសវត្សនៃការតស៊ូរបស់ស្ត្រី ដើម្បីឲ្យមានការចូលរួមស្មើភាពគ្នារវាងបុរស និងស្ត្រីនៅក្នុងសង្គម ។

> **គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា**
> គោលដៅទី៣៖ ជំរុញសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី

សិទ្ធិនារីអន្តរជាតិ ៨មិនា គឺជាទិវាដែលត្រូវបានកំណត់ដោយក្រុមស្ត្រីនៅជុំវិញពិភពលោក។ ទិវានេះក៏ត្រូវបានប្រារព្ធនៅអង្គការសហប្រជាជាតិ និងត្រូវបានកំណត់ជាថ្ងៃឈប់សម្រាកជាតិនៅក្នុងប្រទេសជាច្រើន [១]

អង្គការវិទ្យាស្ថានបើកទូលាយបានកំណត់យកប្រធានបទ **«ស្ត្រីចូលរួមក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងការងារសង្គមជាតិ»** ដើម្បីចូលរួមអបអរសាទរទិវានារីអន្តរជាតិ ៨មិនា ឆ្នាំ២០០៩នេះ ដែលស្របតាមប្រធានបទដែលកំណត់ដោយក្រសួងកិច្ចការនារី និងក្នុងគោលបំណងចូលរួមក្នុងការឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ជាពិសេសគោលដៅទី៣ ដែលបានចែងថា **«ជំរុញសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី»**[២] ។ អង្គការវិទ្យាស្ថានបើកទូលាយមានគោលបំណងផ្សព្វផ្សាយឲ្យបានទូលំទូលាយ នូវការយល់ដឹងអំពីសមភាពយេនឌ័រដល់ស្ត្រីខ្មែរ និងអំពីការចូលរួមរបស់ស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងការងារសង្គមជាតិ ដើម្បីធ្វើឱ្យស្ថានភាពស្ត្រីកម្ពុជាមានភាពប្រសើរឡើង។ សូមចូលអានអត្ថបទទិវាសិទ្ធិនារី៨មិនា http://women.open.org.kh/km/women_rights_2009។

## ២. គោលបំណង

កម្មវិធីស្ត្រី នៃអង្គការវិទ្យាស្ថានបើកទូលាយរៀបចំសកម្មភាពសម្រាប់ចូលរួមក្នុងទិវាសិទ្ធិនារីអន្តរជាតិ ៨មិនា ក្នុងគោលបំណង៖

១. ចូលរួមលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនអំពីសិទ្ធិស្ត្រី និងជំរុញការអនុវត្តសិទ្ធិស្ត្រីនៅក្នុងប្រទេសកម្ពុជា ឲ្យកាន់តែមានភាពប្រសើរឡើង។

២. បង្កើនកិច្ចសហការ និងពង្រីកនូវវប្បធម៌នៃការចែករំលែកព័ត៌មាន និងបទពិសោធន៍ រវាងស្ថាប័ន

១ ប្រវត្តិទិវាសិទ្ធិនារីនេះត្រូវបានដកស្រង់ចេញពី: http://www.un.org/ecosocdev/geninfo/women/womday97.htm

២ http://www.mop.gov.kh/Default.aspx?tabid=156

និងអង្គការដែលធ្វើការអំពីស្ត្រី និងបុគ្គល អំពីបញ្ហាស្ត្រីក្នុងប្រទេសកម្ពុជា។

## ៣. សកម្មភាពចូលរួមក្នុងទិវាសិទ្ធិនារីអន្តរជាតិ ៨មិនា ឆ្នាំ២០០៩

កម្មវិធីស្ត្រី នៃអង្គការវិទ្យាស្ថានបើកទូលាយ នឹងរៀបចំឲ្យមាននូវសកម្មភាពមួយចំនួន ដូចជា៖

១. **រចនានូវទម្រង់ ឬរូបភាព ឬអក្សរ អំពីទិវានារីអន្តរជាតិ ៨មិនា** ដាក់លើវិបផតថលស្តីអំពីស្ត្រី ។ នៅពេលលោក លោកស្រី អ្នកនាង កញ្ញា យកកណ្តុរទៅដាក់លើរូបភាព/អក្សរនេះ វានឹងចេញជាអក្សរលើរូបភាពនេះអំពីប្រធានបទនៃទិវាសិទ្ធិនារីអន្តរជាតិ៨មិនាឆ្នាំនេះ **«ស្ត្រីចូលរួមក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងការងារសង្គមជាតិ»**។ នៅពេលដែលលោក លោកស្រី អ្នកនាង កញ្ញា ចុចលើរូបនេះ លោកអ្នកនឹងបានឃើញនូវអត្ថបទជាច្រើនទាក់ទងនឹងប្រធានបទខាងលើ និងទាក់ទងនឹងទិវាសិទ្ធិនារីអន្តរជាតិ៨មិនា។

២. **ផ្សព្វផ្សាយអត្ថបទទាក់ទងទិវានារីអន្តរជាតិ៖** កម្មវិធីស្ត្រីនឹងដកស្រង់ផ្សព្វផ្សាយព័ត៌មានសកម្មភាពរបស់ស្ថាប័ននិងអង្គការដែលធ្វើការងារអំពីស្ត្រី និងសិទ្ធិ ព្រមទាំងសូមស្វាគមន៍និងលើកទឹកចិត្តចំពោះលោកអ្នក ក្នុងការចូលរួមសរសេរអត្ថបទ និងព័ត៌មាន សម្រាប់ផ្សព្វផ្សាយលើវិបផតថលស្តីអំពីស្ត្រី។ លោកអ្នកអាចដាក់បញ្ចូលអត្ថបទលើវិបផតថលស្តីអំពីស្ត្រីដោយខ្លួនឯង ឬផ្ញើមកកម្មវិធីស្ត្រី សម្រាប់ដាក់ផ្សព្វផ្សាយជូន ។

៣. **បទវិចារណកថា៖** កម្មវិធីស្ត្រីនឹងធ្វើការផ្សព្វផ្សាយនូវបទវិចារណកថាដែលផ្តោតទៅលើប្រធានបទ **«ស្ត្រីចូលរួមក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងការងារសង្គមជាតិ»** ។

៤. **ចូលរួមសហការ**ជាមួយគណៈកម្មាធិការ លុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (Cambodian NGO Committee on CEDAW) និងចូលរួមជាមួយនឹងស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ក្នុងពិធីអបអរសាទរ ទិវានារីអន្តរជាតិ។

៥. **ការពិភាក្សាតាមរយៈមធ្យោបាយទំនាក់ទំនង**លើវិបផតថលស្តីអំពីស្ត្រី **ចាប់ពីថ្ងៃទី២០ ខែកុម្ភៈ រហូតដល់ថ្ងៃទី ១៣ ខែមិនា ឆ្នាំ២០០៩**។ កម្មវិធីនឹងធ្វើការជំរុញឲ្យមានការពិភាក្សា និងចែករំលែកនូវបទពិសោធន៍ និងចំណេះដឹងរបស់លោក លោកស្រី អ្នកនាង កញ្ញា ជុំវិញប្រធានបទ **«ស្ត្រីចូលរួមក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងការងារសង្គមជាតិ»** តាមរយៈ

- កំណត់ហេតុបណ្តាញ
- វេទិកាលើបណ្តាញ
- បញ្ជីសំបុត្ររួម

ដើម្បីធ្វើការលើកទឹកចិត្ត និងជំរុញឲ្យមានការចូលរួមចែករំលែក និងពិភាក្សាឲ្យកាន់តែមានលក្ខណៈផុលផុសថែមទៀតនោះ កម្មវិធីស្ត្រីនឹងមានចេញជាប័ណ្ណសរសើរជូន លោក លោកស្រី អ្នកនាង កញ្ញា ដែលបានចូលរួមពិភាក្សានៅក្នុងមធ្យោបាយទំនាក់ទំនងទាំងនេះ។

- **លក្ខខ័ណ្ឌនៃការទទួលបាននូវប័ណ្ណសរសើរ៖**
    - កិច្ចពិភាក្សាត្រូវផ្តោតលើប្រធានបទ **«ស្ត្រីចូលរួមក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងការងារសង្គមជាតិ»**
    - ប័ណ្ណសរសើរនឹងត្រូវផ្តល់ជូនចំពោះ លោក លោកស្រី អ្នកនាង កញ្ញា ដែលបានចូលរួមនៅក្នុងការពិភាក្សាមានចំនួនច្រើនជាងគេនៅក្នុងមធ្យោបាយទំនាក់ទំនងណាមួយ ដែលបានរៀបរាប់ជូនខាងលើ។
    - ចំនួនប័ណ្ណសរសើរផ្តល់ជូន៖
        - ប័ណ្ណសរសើរចំនួន ០៣ នឹងត្រូវផ្តល់ជូនលោកអ្នកដែលបានចូលរួមពិភាក្សានៅក្នុងបញ្ជីសំបុត្ររួម
        - ប័ណ្ណសរសើរចំនួន ០១ នឹងត្រូវផ្តល់ជូនលោកអ្នកដែលបានចូលរួមពិភាក្សានៅក្នុងកំណត់ហេតុបណ្តាញ
        - ប័ណ្ណសរសើរចំនួន ០១ នឹងត្រូវផ្តល់ជូនលោកអ្នកដែលបានចូលរួមពិភាក្សានៅក្នុងវេទិកាលើបណ្តាញ

    - ចំពោះលោក លោកស្រី អ្នកនាង កញ្ញា ដែលមានការចូលរួមច្រើនជាងគេលើមធ្យោបាយទំនាក់ទំនងច្រើនជាងមួយ នោះក្រុមការងារស្ត្រីនឹងធ្វើការពិនិត្យលើខ្លឹមសារនៃការចែករំលែករបស់លោក លោកស្រី អ្នកនាង កញ្ញា (ខ្លឹមសារអត្ថបទ)។ អង្គការវិទ្យាស្ថានបើកទូលាយនឹងផ្តល់ជូនជយលាភីដល់ លោក លោកស្រី អ្នកនាង កញ្ញា ក្នុងមធ្យោបាយណាមួយដែលមានខ្លឹមសារល្អជាងគេ។
    - អង្គការវិទ្យាស្ថានបើកទូលាយ សូមស្វាគមន៍ និងលើកទឹកចិត្តបុគ្គលិកនៃអង្គការវិទ្យាស្ថានបើកទូលាយក្នុងការចូលរួមការពិភាក្សា។ រាល់ការចូលរួមទាំងនេះនឹងមិនត្រូវបានរាប់បញ្ចូលសម្រាប់ការផ្តល់ជូនជាប័ណ្ណសរសើរនោះទេ។

៦. កម្មវិធីស្ត្រី សូមអញ្ជើញ លោក លោកស្រី អ្នកនាង កញ្ញា ចូលរួមបោះឆ្នោតលើវិបផតថលស្តីអំពីស្ត្រី ដែលមានខ្លឹមសារថា តើស្ត្រីពិតជាបានចូលរួមនៅក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងការងារសង្គមឬ?

៧. កម្មវិធីស្ត្រីនឹងធ្វើការទំនាក់ទំនងសម្រាប់កិច្ចសហការជាមួយបណ្តាក្រុមហ៊ុនបម្រើសេវាកម្មទូរស័ព្ទមួយចំនួន សម្រាប់ការផ្ញើសារជារូបភាពក្នុងទិវាអន្តរជាតិ៨មិនា ឆ្នាំ២០០៩។ សារជារូបភាពនេះមានអត្ថន័យដូចខាងក្រោម៖

**លើកកម្ពស់សិទ្ធិស្ត្រី ដោយប្រើ**
**វិបផតថលស្តីអំពីស្ត្រី**
http://women.open.org.kh

រៀបចំដោយ៖ កម្មវិធីស្ត្រី នៃអង្គការវិទ្យាស្ថានបើកទូលាយ
ភ្នំពេញ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០០៩